ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

**ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)**








# របាយការណ៍វិភាគស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ប្រចាំ៩ខែ ឆ្នាំ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**លេខ:** ........០៤ របក...................**ក.ស.វ.**

ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥

# របាយការណ៍

## ស្តីពី

## ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានកម្ពុជា

## ប្រចាំ៩ខែ ឆ្នាំ២០២៤*

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(**ក.ស.វ.**) ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានកម្ពុជាប្រចាំ៩ខែ ឆ្នាំ២០២៤ ដោយផ្អែកលើទិន្នន័យទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ជាធាតុចូលពីកិច្ចប្រជុំទូលាយ **ក.ស.វ.** ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងកិច្ចប្រជុំចង្អៀតផ្ទៃក្នុង **ក.ស.វ.** ដោយឈរលើគោលការណ៍បរិយាបន្ននៃសេចក្តីវិនិច្ឆ័យ រួមមានខ្លឹមសារសង្ខេបដូចខាងក្រោម។

## I. ការពិពណ៌នាទិន្នន័យតារាង

### ១_ ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់(តារាងទី១)

➡ នាត្រីមាសទី៣ ឆ្នាំ២០២៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,១% ធៀបនឹងត្រីមាសមុន និងកើនឡើង១,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១_ បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន សម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ | | មុខទំនិញ | |
|---|---|---|---|
| សម្លៀកបំពាក់និងស្បែកជើង | +៣,៥% | បន្លែ | +៥,៦% |
| សុខាភិបាល | +៣,០% | ផ្លែឈើ | +២,២% |
| ការសិក្សា | +២,៧% | សាច់មាន់ | +០,៧% |
| ម្ហូបអាហារ | +១,៣% | អង្ករ | +០,៥% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ | +១,០% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | |
|---|---|---|---|
| ទំនិញនិងសេវាកម្មផ្សេងៗ<br>ការកម្សាន្តនិងវប្បធម៌<br>ភោជនីយដ្ឋាន | +០,៧%<br>+០,៧%<br>+០,៥% | ត្រីស្រស់<br>សាច់ជ្រូក<br>សាច់គោ | +០,៤%<br>+០,១%<br>-០,៤% |

តារាង១.២- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអតិផរណាតាមត្រីមាសនិងឆ្នាំ (២០២០-២០២៤), ២០០៦=១០០

| ឆ្នាំ | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|
| ២០២០ | សន្ទស្សន៍ | 181.0 | 181.5 | 183.1 | 185.0 | 182.7 |
| | អតិផរណា | 3.0% | 2.5% | 2.8% | 3.4% | 3.0% |
| ២០២១ | សន្ទស្សន៍ | 184.8 | 186.6 | 189.0 | 191.5 | 188.0 |
| | អតិផរណា | 2.1% | 2.8% | 3.2% | 3.5% | 2.9% |
| ២០២២ | សន្ទស្សន៍ | 195.7 | 200.4 | 198.3 | 197.7 | 198.0 |
| | អតិផរណា | 5.9% | 7.4% | 4.9% | 3.2% | 5.3% |
| ២០២៣ | សន្ទស្សន៍ | 199.5 | 201.5 | 203.3 | 203.8 | 202.0 |
| | អតិផរណា | 1.9% | 0.5% | 2.5% | 3.1% | 2.0% |
| ២០២៤ | សន្ទស្សន៍ | 199.0 | 203.0 | 205.3 | 206.9 P | 203.6 P |
| (P = ព្យាករណ៍) | អតិផរណា | -0.2% | 0.8% | 1.0% | 1.5% P | 0.8% P |

តារាង១.៣_ អត្រាប្តូរប្រាក់

| បរិយាយ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ |
|---|---|---|
| **៛/ដុល្លារ** | ៤ ០៦១៛/$ | ៤ ១៥៨៛/$ |
| **៛/បាត** | ១២៥៛/បាត | ១១៨៛/បាត |
| **៛/ដុង** | ០,១៦៥៛/ដុង | ០,១៧២៛/ដុង |
| **បាត/ដុល្លារ** | ៣២,២បាត/$ | ៣៥,០បាត/$ |
| **ដុង/ដុល្លារ** | ២៤ ៥៦២ដុង/$ | ២៤ ០៩៩ដុង/$ |
| **យ៉ន់/ដុល្លារ** | ៧,០យ៉ន់/$ | ៧,៣យ៉ន់/$ |

## ២_ ស្ថានភាពថវិកាជាតិ (តារាងទី២)

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

តារាង ២.១_ ចំណូលថវិកាជាតិ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៤ (ប៊ីលានរៀល)

| ឆ្នាំ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|
| ២០២០ | 5544 | 5700 | 5225 | 6401 | 22870 |
| ២០២១ | 6095 | 5511 | 4309 | 5287 | 21203 |
| ២០២២ | 6348 | 8047 | 5883 | 6417 | 26695 |
| ២០២៣ | 6766 | 7785 | 5628 | 6609 | 26787 |
| ២០២៤ | 6816 | 6512 | 6011 | - | - |

**២.១_ ចំណូលថវិកាជាតិ** : អនុវត្តបាន៦ ០១១,០ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៤៨០,២លានដុល្លារ ( *មធ្យមប្រចាំខែ៩២,១%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៥ ៨៧១,៩ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ ១ ៤៤៥,៩ លានដុល្លារ ( *មធ្យមប្រចាំខែ៩៩,៣% នៃផែនការ*) និងចំណូលមូលធនចំនួន១៣៩,១ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ៣៤,៣លានដុល្លារ ( *មធ្យមប្រចាំខែ១៥,៨% នៃផែនការ*) (តាមតួលេខរតនាគារជាតិ)។

➤បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិថយចុះ៧,៧% ប៉ុន្តែកើនឡើង៦,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២៣។

➤ក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន៥ ៧៣០,៩ប៊ីលានរៀលថយចុះ៥,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៦,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន៥ ០៨៩,៧ប៊ីលានរៀលថយចុះ៦,៦% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង៧,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ ចំណូលមិនមែនសារពើពន្ធ មានចំនួន៧៨២,២ប៊ីលានរៀលថយចុះ១២,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង ២៩,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១_ មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ បម្រែបម្រួល ធៀបនឹងត្រីមាស.. | | | ចំណូលមិនមែនសារពើពន្ធ បម្រែបម្រួល ធៀបនឹងត្រីមាស.. | | |
|---|---|---|---|---|---|
| | មុន | ដូចគ្នាឆ្នាំមុន | | មុន | ដូចគ្នាឆ្នាំមុន |
| ពន្ធនិងអាករគយ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | +២,៨% | +១៧,៧% | អាជ្ញាបណ្ណក្នុងស្រុក | +៤៦០,៥% | -៨,១% |
| | | | កម្រៃការគ្រប់គ្រង និង ទិដ្ឋាការនាំចេញ | +៣៣,៧% | +៨៩,០% |
| | | | សម្បទានរ៉ែ | -៦,៦% | +៣៩,៤% |
| ចំណូលពន្ធដារ (អគ្គនាយកដ្ឋានពន្ធដារ) | -១២,១% | -២,២% | អាកាសចរណ៍ស៊ីវិល | +៧,៥% | +១៦,៦% |
| | | | ផលទុននៃសកម្មភាព ទេសចរណ៍ | -២,៥% | +៤៤,២% |

**២.២_ ចំណាយថវិកាជាតិ** : អនុវត្តបាន៥ ៨២២,៨ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៤៣៣,៨លានដុល្លារ ( *មធ្យមប្រចាំខែ៨៥,៥%នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន៤ ៨៨១,៦ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ ១ ២០២,១លានដុល្លារ( *មធ្យមប្រចាំខែ១០៧,៦%នៃផែនការ*) និងចំណាយមូលធនមានចំនួន៩៤១,២ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ២៣១,៨ លានដុល្លារ(តាមតួលេខ រតនាគារជាតិ)។ ចំណាយថវិកាជាតិថយចុះ៤,៧% ធៀបនឹងត្រីមាសមុន និងថយចុះ១១,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៣,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែ កើនឡើង៤,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង ២.២_ ចំណាយថវិកាជាតិ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៤ (ប៊ីលានរៀល)

| ឆ្នាំ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|
| ២០២០ | 4784 | 5254 | 5113 | 7175 | 22326 |
| ២០២១ | 5366 | 4746 | 6333 | 6475 | 22920 |
| ២០២២ | 5889 | 5061 | 5433 | 5722 | 22105 |
| ២០២៣ | 5999 | 6046 | 6601 | 8578 | 27225 |
| ២០២៤ | 7578 | 6110 | 5823 | - | - |

**២.៣_ សមតុល្យថវិកាជាតិ** ៖ ថវិកាជាតិនាត្រីមាសទី៣នេះ មានអតិរេកចំនួន១៨៤,២ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ៤៦,៣លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣_ ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាងទី៣)

➡សូចនាកររូបិយវត្ថុផ្សេងៗនាត្រីមាសទី៣ ឆ្នាំ២០២៤មានលក្ខណៈដូចខាងក្រោម៖

| *បរិយាយ* | ត្រីមាស៣ ២០២៤ | ត្រីមាស៣ ២០២៣ | %Δ |
|---|---|---|---|
| | ប៊ីលានរៀល | | |
| រូបិយវត្ថុ M2 | ២១៧ ៩១៨,៩ | ១៨៧ ២៣៧,៥ | +១៦,២% |
| រូបិយវត្ថុ M1 | ៤៦ ៩៩៦,១ | ៤២ ២៨១,៧ | +១១,១% |
| (៛) ក្រៅគ្រឹះស្ថាន | ១៥ ៣៦៤,៥ | ១៤ ៥១៦,៨ | +៥,៨% |
| ប្រាក់បញ្ញើចរន្ត | ៣១ ៦៣១,៦ | ២៧ ៧៦៥,០ | +១៣,៩% |
| ប្រាក់បញ្ញើផ្សេងទៀត | ១៧០ ៩២២,៨ | ១៤៤ ៩៥៥,៨ | +១៧,៦% |

➡ ក្រាហ្វខាងក្រោមបង្ហាញសមាមាត្រនៃ ប្រាក់រៀលនៅក្រៅធនាគារ (C) ប្រាក់បញ្ញើចរន្ត (DD) និងប្រាក់បញ្ញើផ្សេងទៀត (**Quasi-Money**)។ [សម្គាល់ : C + DD = M1 M1 + Quasi-Money = M2]។

ក្រាហ្វ៣.១_ សមាសធាតុរូបិយវត្ថុ

ត្រីមាសទី៣ ឆ្នាំ២០២៤ ត្រីមាសទី៣ ឆ្នាំ២០២៣




➡ សមាមាត្រនៃ ការផ្គត់ផ្គង់ប្រាក់រៀល (ក្នុងនិងក្រៅធនាគារ) និងប្រាក់បញ្ញើជារូបិយបណ្ណ មានដូចតារាងខាងក្រោម។

តារាង៣.១_ សមាមាត្រចំនួនប្រាក់រៀល និងប្រាក់បញ្ញើជារូបិយបណ្ណ ក្នុង $M_2$ ឆ្នាំ២០២៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រូបិយបណ្ណបរទេស នៅក្នុងធនាគារ | ៨៣,៦% | ៨៣,៤% | ៨៣,៦% | ៨៣,៨% | ៨៤,២% | ៨៤,២% | ៨៤,២% | ៨៤,៣% | ៨៤,២% | | | |
| ប្រាក់រៀលសរុប ក្នុង&ក្រៅគ្រឹះស្ថាន | ១៦,៤% | ១៦,៦% | ១៦,៤% | ១៦,២% | ១៥,៨% | ១៥,៨% | ១៥,៨% | ១៥,៧% | ១៥,៨% | | | |

ក្រាហ្វ៣.២_បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ( ក្នុងវង់ក្រចក = %Δ ធៀបនឹងត្រីមាសដូចគ្នា )




---

តារាង៣.៣_ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំត្រីមាស

| *បរិយាយ* | *ត្រីមាសទី៣ ២០២៤* | *ត្រីមាសទី៣ ២០២៣* | *%Δ* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ២២៥ ៦០១,៧<br>២៥ ៣៥៣,៤ | ២២០ ០៣៧,៩<br>២៤ ១៨១,៧ | +២,៥%<br>+៤,៨% |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ប៊ីលានរៀល) | ២១ ៤៥៥,១ | ២១ ២៣៩,១ | +១,០% |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៣% | ៦,៦% | -២០,០% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៦% | ៥,៨% | -២១,៥% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៥% | ១២,០% | -៣,៨% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៩,៧% | ១០,០% | -២,៣% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៦,៧% | ១៦,៧% | +០,១% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៧% | ១៧,៨% | -០,៥% |

## ៤_ ស្ថានភាពកសិកម្ម រ៉ែនិងថាមពល ឧស្សាហកម្ម សំណង់ សេវាកម្ម ការងារ វិនិយោគ ទំនិញឆ្លងកាត់តាមកំពង់ផែ ការចុះបញ្ជីនិងចរាចរណ៍ ប្រៃសណីយ៍និងទូរគមនាគមន៍ អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ ទេសចរណ៍ និងបរិស្ថាន (តារាងទី៤)

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម

➢**កសិកម្ម**:

✓ផលិតផលជលផលសម្រេចបាន១៦៨,៥៣ពាន់តោន កើនឡើង៨,៣%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ១៨,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ផ្ទៃដីដាំកៅស៊ូសរុបមាន៤០៧,២ ពាន់ហិកតា ស្ថិតនៅដដែលធៀបនឹងត្រីមាសមុន និងកើនឡើង០,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

–ផលិតផលកៅស៊ូមានចំនួន ១០៩,៣ពាន់តោន កើនឡើង៥០,៣% ធៀបនឹងត្រីមាសមុន និងកើនឡើង ៥,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

–ចំណូលពីការនាំចេញកៅស៊ូមានចំនួន១៨០,៧ លានដុល្លាកើនឡើង៥៩,៩%ធៀបនឹងត្រីមាសមុន និងកើនឡើង៣៥,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤ ៨៧៥,៧ GWh ថយចុះ៥,៩%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១៤,០%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

– អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីចំនួន៣ ០៣៩,៣GWh (៦២,៣%នៃការផ្គត់ផ្គង់ដោយ EDC) កើនឡើង ១៥១,៤% ធៀបនឹងត្រីមាសមុន និងកើនឡើង៦,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មចំនួន១ ៤២៣,៤GWh (២៩,២% នៃការផ្គត់ផ្គង់ដោយ EDC) ថយចុះ៤៧,៨% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង២៧,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យមានចំនួន ២៧៦,១ GWh (៥,៧% នៃការផ្គត់ផ្គង់ដោយ EDC) កើនឡើង១៣,៣%ធៀបនឹងត្រីមាសមុន និងកើនឡើង៤៦,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីនាំចូលពីប្រទេសជិតខាងមានចំនួន១៣២,១GWh (២,៧% នៃការផ្គត់ផ្គង់ដោយ EDC) ថយចុះ៧៨,០% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១៤,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀត មានចំនួន៤,៨GWh (០,១% នៃការផ្គត់ផ្គង់ដោយ EDC) មានការថយចុះ ៩៨,៨% ធៀបនឹងត្រីមាសមុន និងថយចុះ៥៤,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢ផលិតកម្មស៊ីម៉ងត៍មានចំនួន២ ១០៩,៥ ពាន់តោន កើនឡើង១,៧% ធៀបនឹងត្រីមាសមុន និងកើនឡើង១៤,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

តារាង៤.១_ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូចនិងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ចំនួន)

| ប្រភេទ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| -រោងចក្រថ្មីដែលបានចុះបញ្ជី | ៦៩ | ៥១ | +៣៥,៣% |
| -ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ២ ៣១៦ | ២ ០២៦ | +១៤,៣% |
| -ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៣៧១ | ៣០៧ | +២០,៨% |
| -ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ២៨៦ | ៣៥៦ | -១៩,៧% |

➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឱ្យសាងសង់មានចំនួន៣ ៣៨១,៥ពាន់ម² មានការថយចុះ១៨,៧%ធៀបនឹងត្រីមាសមុន និងថយចុះ៣៤,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១ ៣៦៩,៤លានដុល្លារមានការថយចុះ២៤,៧%ធៀបនឹងត្រីមាសមុន និងថយចុះ៣៧,៨%បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២_ សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ (*ពាន់ម²*)

| បរិយាយ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| ▪ លំនៅឋាន | ៧៧១,១ | ៣ ០៦១,២ | -៧៤,៨% |
| ▪ ឧស្សាហកម្ម | ២ ០០៣,២ | ១ ០៨៩,៨ | +៨៣,៨% |
| ▪ពាណិជ្ជកម្ម | ៣៤៣,៣ | ៨៦៣,២ | -៦០,២% |
| ▪ ទេសចរណ៍ | ៣១,៨ | ៧៦,៦ | -៥៨,៥% |
| ▪ផ្សេងៗ | ១៦,០ | ៦,១ | +១៦០,១% |
| អនុញ្ញាតសរុប | ៣ ៣៨១,៥ | ៥ ១៧៣,៧ | |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺឧស្សាហកម្ម៥៩,២% និងលំនៅឋាន២២,៨%នៃផ្ទៃក្រឡាសរុប។

➢សេវាកម្ម

តារាង៤.៣_ការចុះបញ្ជីនិងលុបចេញពីបញ្ជីនៅក្រសួងពាណិជ្ជកម្ម (*ចំនួន*)

| ប្រភេទ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ៤៤២ | ១ ២០៨ | +១៩,៤% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤០៩ | ២៦៦ | +៥៣,៨% |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៥០០ | ១ ៣៦៣ | +១០,១% |
| ការស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | ១៧ | ៧ | +១៤២,៩% |
| ក្នុងនោះៈលិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៩ | ២ | +៣៥០,០% |

## ➢ការងារ

តារាង៤.៤_ ការស្វែងរកការងារនិងទទួលបានការងារ ( *នាក់*)

| *ប្រភេទ* | *ត្រីមាសទី៣ ២០២៤* | *ត្រីមាសទី៣ ២០២៣* | *%Δ* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ១២ ១៥៦ | ៧ ៧៦៥ | +៥៦,៥% |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៩៣ ៨១៩ | ១០៣ ៦៥១ | -៩,៥% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៧៩ ៤៧៥ | ៨៥ ៦៤៨ | -៧,២% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៤ ៣៤៤ | ១៨ ០០៣ | -២០,៣% |

## ➢ វិនិយោគ

តារាង៤.៥_គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក.( ថ្មីនិងពង្រីក)

| *ប្រភេទ* | *ត្រីមាសទី៣ ២០២៤* | *ត្រីមាសទី៣ ២០២៣* | *%Δ* |
|---|---|---|---|
| អនុញ្ញាតសរុប( លានដុល្លារ) | ២ ០៦០,៧ | ២ ៦៥៩,៧ | -២២,៥% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៨,៤ | ១៦៥,១ | -៧០,៧% |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខរបស់តំបន់សេដ្ឋកិច្ចពិសេស) | ១ ៩៣២,៤<br>(១ ៥៣៣,០) | ៩៤២,៨<br>(៣៣៤,៣) | +១០៥,០%<br>+៣៥៨,៥% |
| វិស័យទេសចរណ៍ | ៨០,០ | ៨៤,៥ | -៥,៤% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ១ ៤៦៧,២ | - |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១២៥ | ៧៨ | +៦០,៣% |
| បង្កើតការងារ (ពាន់នាក់) | ៨៣,៦ | ១០៤,៥ | -១៩,៩% |

➢**ទំនិញឆ្លងកាត់កំពង់ផែ**( សរុប២កំពង់ផែ) មានចំនួន៣ ៧៨៤,០ ពាន់តោន មានការកើនឡើង៥,២%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ២,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ៖

តារាង៤.៦_ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ

| *ប្រភេទ* | *ត្រីមាសទី៣ ២០២៤* | *ត្រីមាសទី៣ ២០២៣* | *%Δ* |
|---|---|---|---|
| ទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ១ ២៧០,៧ | ១ ៣៣៨,៨ | -៥,១% |
| ទំនិញឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២ ៥១៣,៣ | ២ ៥៦០,០ | -១,៨% |
| ចំនួនកុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ១៦០,២ | ១២៧,៩ | +២៥,២% |
| ចំនួនកុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២៨២,៤ | ២០៤,២ | +៣៨,៣% |

## ➢ការចុះបញ្ជីនិងចរាចរណ៍

តារាង៤.៧_ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី(ពាន់គ្រឿង) | ៨០,៧ | ៦៤,២ | +២៥,៧% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១៣,៦ | ១២,១ | +១៣,០% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ៧១០ | ៨៨០ | -១៩,៣% |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៤២,៦ | ៣៨,៤ | +១១,០% |
| ក្នុងនោះទទួល | ១៥,៦ | ១០,៤ | +៤៩,៧% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩៧,៣ | ១០១,១ | -៣,៨% |
| ក្នុងនោះទទួល | ៥២,៨ | ៥២,២ | +១,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ៣៣៧,១ | ១ ៤១២,៨ | -៥,៤% |
| ក្នុងនោះហៅចូល | ៥១៩,៤ | ៤៤៥,៣ | +១៦,៦% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣ ៤៨៧,៦ | ៥ ៤៤៩,២ | -៣៦,០% |
| ក្នុងនោះហៅចូល | ៣ ៤៦៦,៦ | ៥ ៤២៤,៣ | -៣៦,១% |

## ➢ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨_អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍ (*ពាន់នាក់*)

| ប្រភេទ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២០,៣ | ១៦,៦ | +២២,៣% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ១៧៧,៩ | ១៥៣,៨ | +១៥,៧% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានព្រះវិហារ | ១,៨ | ១,៨ | -២,០% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានកោះកេរ | ៣,០ | ២,៥ | +២៣,៦% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានសំបូរព្រៃគុក | ២,២ | ១,៨ | +២៣,៤% |
| អ្នកដំណើរតាមផ្លូវអាកាស(ក្នុងស្រុក) | ៦៨,៩ | ៣៥,៨ | +៩២,៤% |
| អ្នកដំណើរតាមផ្លូវអាកាស(អន្តរជាតិ) | ១ ៣៧៩,៥ | ១ ១៦១,៧ | +១៨,៧% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ២១,៨ | ១៦,០ | +៣៦,៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៤៥៧,៣ | ៤៥៨,៦ | -០,៣% |
| ចំនួនទេសចរផ្ទៃក្នុង | ៣ ១៦៥,៤ | ២ ៥៤៣,០ | +២៤,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ៦៣៤,០ | ១ ៣៤៧,០ | +២១,៣% |
| ✓ តាមផ្លូវអាកាស | ៥៥០,៩ | ៤២៧,៩ | +២៨,៧% |
| ✓ តាមផ្លូវគោកនិងផ្លូវទឹក | ១ ០៨៣,២ | ៩១៩,១ | +១៧,៩% |

## ៥_ ស្ថានភាពជញ្ជីងពាណិជ្ជកម្ម(តារាងទី៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាត្រីមាសទី៣ ឆ្នាំ២០២៤ មានចំនួន២៨ ៤២២,៣ប៊ីលានរៀល (ស្មើនឹង៦ ៩៩៨,៩ លានដុល្លារ) ថយចុះ១,៤%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង២៣,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១- ការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | ត្រីមាសទី៣ ២០២៤ | ត្រីមាសទី៣ ២០២៣ | %∆ |
|---|---|---|---|
| ប្រេងសាំង | ២៥៧,៩ | ២៥៦,៥ | +០,៥% |
| ប្រេងម៉ាស៊ូត | ៤៦៨,៧ | ៤០៥,៨ | +១៥,៥% |
| ឧស្ម័ន | ១២៥,៥ | ១១៦,១ | +៨,១% |
| អគ្គិសនីនាំចូលដោយ EDC | ១៣២,១ | ១១៥,៧ | +១៤,២% |
| ដែកសំណង់ | ២១៦,០ | ១១៥,៣ | +៨៧,៣% |
| ស៊ីម៉ងត៍ | ៤៥,៤ | ៨៣,៣ | -៤៥,៤% |
| ជីកសិកម្ម | ២៨៧,៣ | ២១៥,៣ | +៣៣,៤% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | ៤០,០ | ៤១,៨ | -៤,៥% |
| រថយន្តសរុប (ប៊ី.ល.រ) | ១ ០៥៨,០ | ៩២៤,៨ | +១៤,៤% |
| រថយន្តសរុប (គ្រឿង) | ១០ ២២៥,០ | ១១ ២៨១,០ | -៩,៤% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | ៤ ៦៦៩,០ | ២ ៤៧២,០ | +៨៨,៩% |
| ស្រូវសាលី | ៤៩,២ | ២៨,៨ | +៧១,០% |
| ផ្លែឈើនិងបន្លែ | ២៤,៩ | ២៤,០ | +៣,៦% |
| ថ្នាំកសិកម្ម | ២០,៤ | ១៦,៥ | +២៣,៨% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | ៨ ៤៩៨,២ | ៧ ៥៧៦,៧ | +១២,២% |

➡ **ការនាំចេញ** ត្រីមាសទី៣ ឆ្នាំ២០២៤ មានចំនួន២៩ ៥០៣,៦ប៊ីលានរៀល ស្មើនឹង៧ ២៦៥,១លានដុល្លារ (១០៣,៨% នៃការនាំចូល) កើនឡើង២៧,៤%ធៀបនឹងត្រីមាសមុន និងកើនឡើង២៥,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២_បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | *ត្រីមាសទី៣ ២០២៤* | *ត្រីមាសទី៣ ២០២៣* | %∆ |
|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | ១៧ ១១៦,១ | ១២ ៧៣៤,៥ | +៣៤,៤% |
| អង្ករ | ១០៥,៤ | ១៣២,៩ | -២០,៧% |
| ផលិតផលនេសាទ | ៦២,១ | ៨០,៣ | -២២,៨% |
| កៅស៊ូ | ៨០,៤ | ៩០,១ | -១០,៧% |
| ខ្សាច់ | ១០ ៦៦២,៣ | ៤ ៦៥៨,៧ | +១២៨,៩% |

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ឆែម គាតរិទ្ធី

# សហគមន៍នេសាទព្រែកត្នោត ខេត្តកំពត










ក្រុមបច្ចេកទេសរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន

អាសយដ្ឋាន: អគារមិត្តភាព លេខ៨១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: ០៨៥ ៧៧៧ ៩៨០ / ០១២ ៦៦២ ៣១៦ ទូរសារ: ០២៣ ២២១ ៩៨០

Email: chyanit168@gmail.com / mamsarith@yahoo.com